# សេចក្តីប្រកាសព័ត៌មាន

## ថ្ងៃទី ២៦ មិថុនាឆ្នាំ ២០០៧

## កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលអនុវត្តគំរោង

កិច្ចប្រជុំលើកទីមួយរបស់ក្រុមប្រឹក្សាភិបាលអនុវត្តគំរោងសំរាប់ ជំនួយពិសេសដល់ភាគីកម្ពុជាទៅលើថវិកាសំរាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រារព្ធធ្វើឡើងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កាលពី ថ្ងៃ សុក្រ ទី ២២ ខែមិថុនា ឆ្នាំ ២០០៧។ គំរោងនេះអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាព្រមទាំងចូលរួមជាវិភាគទានសំរាប់ថវិកាផ្នែកខាងភាគីកម្ពុជា។

សំរាប់ជំនួយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ(UNDP) នៅក្នុងគំរោងនេះគឺទទួលបានមកពីម្ចាស់ជំនួយជាច្រើនដូចជាជំនួយចំនួន ៥.៣ លានដុល្លា (ប្រាំចុចបីលានដុល្លា) ពីមូលនិធិអង្គការសហប្រជាជាតិតាមរយៈការិយាល័យសង្គមនិងសេដ្ឋកិច្ចរបស់អង្គការសហប្រជាជាតិ (UNDESA) និងចំនួន ១ លានអឺរ៉ូ (១.៣លានដុល្លា) ពី សហគមន៍អឺរ៉ុប។
ក្រុមប្រឹក្សាភិបាលអនុវត្តគំរោងមានភារកិច្ចទទួលខុសត្រូវ ផ្តល់នូវការត្រួតពិនិត្យទូទៅ ការពិនិត្យសារឡើងវិញនូវការវិវត្តន៍លើការអនុវត្តន៍សកម្មភាពនិងផ្តល់ជាអនុសាសន៍ចាំបាច់ដើម្បីកែប្រែសកម្មភាពគំរោងទៅតាមតំរូវការ។
ភាគីនៃក្រុមប្រឹក្សាភិបាលអនុវត្តគំរោងនេះរួមមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) ការិយាល័យសង្គមនិងសេដ្ឋកិច្ចរបស់អង្គការសហប្រជាជាតិ (UNDESA) និងសហគមន៍អឺរ៉ុបដោយមានប្រធានការិយាល័យរដ្ឋបាលដែលតំណាងឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាធ្វើជាប្រធានក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាលអនុវត្តគំរោងនេះត្រូវបានបង្កើតឡើងដោយយោងតាមកិច្ចព្រមព្រៀងលើគំរោងជំនួយបច្ចេកទេសរវាងរាជរដ្ឋាភិបាលកម្ពុជា កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) និងអង្គការសហប្រជាជាតិ (UN) ដែលបានចុះហត្ថលេខានា ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៦។

នៅក្នុងកិច្ចប្រជុំកាលពីថ្ងៃសុក្រផងដែរ ក៏មានការព្រមព្រៀងគ្នានូវផែនការការងារនិងហិរញ្ញវត្ថុប្រចាំឆ្នាំ២០០៧ ដោយផ្អែកទៅតាមការពិនិត្យសារឡើងវិញលើការវិវត្តន៍ដែលកើតមានចាប់តាំងពីការចាប់ផ្តើមសកម្មភាព ការងាររបស់គំរោងនេះ។ បន្ថែមលើនេះទៅទៀត ក្រុមប្រឹក្សាភិបាលអនុវត្តគំរោង ក៏បានពិចារណាផងដែរទៅលើអនុសាសន៍ធ្វើឡើងដោយការិយាល័យធ្វើសវនកម្មនិងពិនិត្យរបស់ កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) នៅក្នុងរបាយការណ៍សវនកម្មសវនកម្មចុងក្រោយរបស់ខ្លួនទៅលើការពង្រឹងសមត្ថភាពរបស់ស្ថាប័នដើម្បីធានាឲ្យបាននូវគុណភាពនិងសុច្ចរិតភាពក្នុងការអនុវត្តន៍ធនធានមនុស្ស។
របាយការណ៍សវនកម្មនេះបានចេញនៅខែមិថុនាឆ្នាំ២០០៧បន្ទាប់ពីបានធ្វើទស្សនកិច្ចចំនួន ២ លើកខែ កុម្ភៈ និងខែ មីនា ឆ្នាំ ២០០៧។
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានយល់ព្រមទៅតាមអនុសាសន៍ទាំងនោះដែលបានលើកឡើងទៅកាន់ភាគីរបស់ខ្លួន ហើយព្រមទាំងបានចាប់ផ្តើមអនុវត្តរួចមកហើយដែរ។ ការពិភាក្សាពិស្តារត្រូវបានរៀបចំឡើងដើម្បីតាមដានសកម្មភាពដែលត្រូវធ្វើនៅក្នុងខែបន្ទាប់។

## ប្រវត្តិ

នៅក្រោមលក្ខខណ្ឌកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា អាណត្តិរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺដើម្បីនាំកាត់ទោសមេដឹកនាំធំៗរបស់របបកម្ពុជាប្រជាធិបតេយ្យនិងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតទៅលើឧក្រិដ្ឋកម្មនិងការរំលោភធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិនិងទំលាប់អន្តរជាតិនិងអនុសញ្ញាអន្តរជាតិនានាដែលទទួលស្គាល់ដោយកម្ពុជា ដែលបានធ្វើឡើងក្នុងរយៈពេលពីថ្ងៃទី ១៧ មេសា ១៩៧៥ ដល់ ថ្ងៃទី ៦ មករា ១៩៧៩។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាតុលាការកូនកាត់ដែលរួមមានមន្ត្រីច្បាប់ថ្នាក់ជាតិនិងអន្តរជាតិហើយធ្វើការទៅតាមច្បាប់ជាតិនិងអន្តរជាតិ។